California's protection & advocacy system

# សេវាបន្ថែមសម្រាប់កុមារ និងយុវជន ដែលស្ថិតនៅក្រោមកម្មវិធី Medi-Cal EPSDT

*ឯកសារផ្សព្វផ្សាយសម្រាប់ខែមេសា ឆ្នាំ 2018 #5526.06 - Cambodian*

**1. តើសេវាអ្វីខ្លះដែលខ្ញុំអាចទទួលបានពី Medi-Cal[1] ដែលស្ថិតនៅក្រោម EPSDT?**

ពាក្យពេញរបស់ EPSDT គឺការត្រួតពិនិត្យ ការធ្វើរោគវិនិច្ឆ័យ និងការព្យាបាលនៅដំណាក់កាលដំបូង និងយ៉ាងទៀងទាត់។ EPSDT គឺជាអត្ថប្រយោជន៍មួយនៃ Medi-Cal។ ប្រសិនអ្នកមានអាយុក្រោម 21 និងមាន Medi-Cal ដ៏ពេញលេញ,[2] អ្នកនឹងទទួលបានអត្ថប្រយោជន៍នៃ EPSDT។[3]

EPSDT ផ្តល់ជូនអ្នកនូវអត្ថប្រយោជន៍នៃការថែទាំសុខភាពមួយចំនួន។

**ការត្រួតពិនិត្យយ៉ាងទៀងទាត់**—ទីមួយ EPSDT និយាយថា Medi-Cal ត្រូវតែផ្តល់ជូនអ្នកនូវការត្រួតពិនិត្យយ៉ាងទៀងទាត់ដើម្បី កំណត់អំពីតម្រូវការក្នុងការថែទាំសុខភាពរបស់អ្នក។ នេះរួមបញ្ចូលទាំងការត្រួតពិនិត្យអំពីតម្រូវការផ្នែកសោតវិញ្ញាណ ផ្នែកចក្ខុវិញ្ញាណ ផ្នែកទន្តសាស្ត្រ និងផ្នែកសុខភាពខួរក្បាលផងដែរ។ វាក៏រួមបញ្ចូលការត្រួតពិនិត្យការបំពុលដោយសារថ្នាំលាបដែលមាន សារធាតុសំណផងដែរ។

**សេវាធ្វើរោគវិនិច្ឆ័យ និងសេវាព្យាបាល**—ទីពីរ នៅពេលដែល អ្នកមានតម្រូវការក្នុងការថែទាំសុខភាព EPSDT និយាយថា Medi-Cal ត្រូវតែផ្តល់ជូនអ្នកនូវសេវាធ្វើរោគវិនិច្ឆ័យ និងសេវាព្យាបាលដើម្បី "កែតម្រូវ ឬធ្វើឲ្យប្រសើរឡើង" ចំពោះស្ថានភាពរបស់អ្នក។

**សេវាថែទាំវេជ្ជសាស្ត្រណាមួយដែលអាចត្រូវទូទាត់ប្រាក់ដើម្បី ទទួលបានសេវានោះនៅក្នុងកម្មវិធី Medicaid**—EPSDT ផ្តល់ជូននូវ សេវាថែទាំវេជ្ជសាស្ត្រខុសៗគ្នាជាច្រើន ដែលរួមបញ្ចូលទាំងសេវានានាដែល មិនមាននៅក្នុងបញ្ជីសេវា Medi-Cal ធម្មតាដែលអាចស្វែងរកបានសម្រាប់

អ្នកដែលមានអាយុ 21 ឆ្នាំឡើងទៅផងដែរ។ នេះពីព្រោះតែរដ្ឋកាលីហ្វ័រញ៉ាអាចជ្រើសរើសដាក់កំហិតលើសេវានានាដែលខ្លួនស្នើផ្តល់ជូនមនុស្សពេញវ័យ ប៉ុន្តែស្នើផ្តល់សេវាទាំងនោះជូនកុមារដែលមានអាយុក្រោម 21 ឆ្នាំ រដ្ឋត្រូវតែស្នើផ្តល់នូវសេវាណាមួយដែលកម្មវិធី Medicaid អាចទូទាត់ប្រាក់សម្រាប់សេវានោះ ទោះបីជារដ្ឋបានជ្រើសរើសមិនផ្តល់សេវានោះជូនមនុស្សពេញវ័យក៏ដោយ។

ឧទាហរណ៍នានារួមមាន សេវាបន្ថែមផ្នែកទន្តសាស្ត្រ សេវាផ្នែកចក្ខុវិញ្ញាណ សេវាផ្នែកសោតវិញ្ញាណ, សេវាថែទាំដោយគិលានុប្បដ្ឋាក-យិកាឯកជន (ការថែទាំដោយប្តូរវេនគ្នា) ពីគិលានុប្បដ្ឋាក-យិកាមធ្យម (RN) ឬគិលានុប្បដ្ឋាក-យិកាដែលបានឆ្លងកាត់ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងមានអាជ្ញាប័ណ្ណ (LVN), ការគ្រប់គ្រងករណី, ការថែទាំសុខភាពកុមារនៅពេលថ្ងៃ, ការវាយតម្លៃអំពីចំណីអាហារ និងសេវាចំណីអាហារ, និងការវាយតម្លៃអំពីសុខភាពខួរក្បាល និងសេវាផ្នែកសុខភាពខួរក្បាល។ ការវាយតម្លៃអំពីសុខភាពខួរក្បាល និងសេវាផ្នែកសុខភាពខួរក្បាល រួមបញ្ចូលទាំងសេវាផ្នែកឥរិយាបថនៃការព្យាបាល (TBS) និងសេវាផ្នែកឥរិយាបថនៅក្នុងផ្ទះ (IHBS) និងការសម្របសម្រួលការថែទាំសម្រាប់អ្នកជំងឺកម្រិតធ្ងន់ (ICC) ផងដែរ។ [4]

## 2. តើ EPSDT ខុសគ្នាពី Medi-Cal យ៉ាងដូចម្តេចខ្លះ?

EPSDT មិនខុសគ្នាពី Medi-Cal នោះទេ - វាគឺជាផ្នែកមួយនៃ Medi-Cal។ វាគ្រាន់តែជាអត្ថប្រយោជន៍បន្ថែមមួយដែលអ្នកទទួលបានពីព្រោះអ្នកមានអាយុក្រោម 21 ឆ្នាំ។ EPSDT មានស្តង់ដារនៃភាពចាំបាច់ផ្នែកវេជ្ជសាស្ត្រដែលសមហេតុផល និងមានការវិនិច្ឆ័យជាក់ស្តែងដើម្បីទទួលបានការអនុញ្ញាតសម្រាប់សេវានានា។ នេះមានន័យថាអ្នកអាចទទួលបានការធ្វើតេស្ត និងសេវាច្រើនជាងការធ្វើតេស្ត និងសេវាដែលអ្នកនឹងអាចទទួលបានប្រសិនបើអ្នកមានអាយុ 21 ឆ្នាំឡើងទៅ ប្រសិនបើវេជ្ជបណ្ឌិត ឬអ្នកដែលមានវិជ្ជាជីវៈផ្នែកព្យាបាលរបស់អ្នកបានណែនាំឲ្យមានការធ្វើតេស្ត ឬការប្រើប្រាស់សេវាឯបែបនោះ។ រដ្ឋត្រូវតែយល់ព្រមថា សេវានានា “មានភាពចាំបាច់ផ្នែកវេជ្ជសាស្ត្រ”។

## 3. តើស្តង់ដារនៃភាពចាំបាច់ផ្នែកវេជ្ជសាស្ត្ររបស់ EPSDT គឺជាអ្វី?

សេវានានាដែលស្ថិតនៅក្រោម EPSDT មានភាពចាំបាច់ផ្នែកវេជ្ជសាស្ត្រ ប្រសិនបើសេវាទាំងនោះត្រូវបានគេរំពឹងទុកថានឹង "កែតម្រូវ ឬធ្វើឲ្យប្រសើរឡើងចំពោះវិការៈ និងជំងឺ និងស្ថានភាពផ្លូវកាយ និងផ្លូវចិត្តនានា។[5]

## 4. តើខ្ញុំនឹងទទួលបាន EPSDT ដែរឬទេ ប្រសិនបើខ្ញុំមាន MAGI Medi-Cal?

បាទ/ចាស អ្នកនឹងទទួលបានប្រសិនបើអ្នកមានអាយុក្រោម 21 ឆ្នាំ។ ច្បាប់ស្តីពីការថែទាំដែលមានតម្លៃសមរម្យបានបង្កើនចំនួនប្រជាជនដែលអាចមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការទទួលបាន Medi-Cal។ ប្រាក់ចំណូលដុលដែលត្រូវបានកែប្រែ និងត្រូវបានកែសម្រួល (MAGI) គឺជាវិធីសាស្ត្រក្នុងការកំណត់សិទ្ធិទទួលបានផ្នែកហិរញ្ញវត្ថុសម្រាប់ក្រុមប្រជាជនដែលមានចំនួនកាន់តែច្រើនឡើងនេះ ព្រមទាំងសម្រាប់ឥណទានពន្ធលើបុព្វលាភ និងការជួយចែករំលែកសោហ៊ុយ តាមរយៈ Covered California។[6] ប្រជាជនដែលស្ថិតនៅក្នុងកម្មវិធី MAGI Medi-Cal ទទួលបានអត្ថប្រយោជន៍ដូចគ្នានឹងអ្នកមាន Medi-Cal ធម្មតាដែរ។[7]

## 5. ចុះប្រសិនបើខ្ញុំមានសេវារបស់កុមារនៃរដ្ឋកាលីហ្វ័រញ៉ា (CCS) វិញនោះ?

CCS គឺជាកម្មវិធីមួយរបស់រដ្ឋសម្រាប់កុមារដែលមានអាយុក្រោម 21 ឆ្នាំដែលមានពិការភាពមួយចំនួន។[8] អ្នកអាចមានទាំង CCS និង Medi-Cal។ អ្នកនៅតែមានសិទ្ធិទទួលបាន EPSDT ដែលស្ថិតនៅក្រោម Medi-Cal ទោះបីជាអ្នកមាន CCS ក៏ដោយ។

## 6. តើការថែទាំដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ Medi-Cal មានអ្វីខ្លះ?

នៅពេលនេះ ជនពិការភាគច្រើនទទួលបាន Medi-Cal របស់ពួកគេតាមរយៈផែនការថែទាំដែលស្ថិតនៅក្រោមការគ្រប់គ្រងមួយ។ ផែនការថែទាំដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ Medi-Cal គឺជាបណ្តាញអ្នកផ្តល់ការថែទាំសុខភាពមួយដែលរួមបញ្ចូលទាំងមន្ទីរពេទ្យ វេជ្ជបណ្ឌិត គ្រូពេទ្យព្យាបាល។ល។ ដែលផ្តល់សេវាថែទាំសុខភាពនានាទៅឲ្យសមាជិករបស់ខ្លួន។ នៅក្នុងផែនការថែទាំដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ Medi-Cal ជាទូទៅ អ្នកត្រូវបានដាក់កំហិតចំពោះអ្នកផ្តល់សេវានៅក្នុងផែនការនេះ។[9] អ្នកជ្រើសរើសគ្រូពេទ្យថែទាំចម្បង (PCP) ម្នាក់ ដែលនឹងសម្របសម្រួល

ការថែទាំរបស់អ្នក និងបញ្ជូនអ្នកទៅកាន់អ្នកឯកទេសណាម្នាក់ ប្រសិនបើចាំបាច់។  នេះខុសពីសេវា Medi-Cal ដែលត្រូវទូទាត់ប្រាក់កម្រៃ (នៅពេលខ្លះត្រូវបានហៅថា Medi-Cal "តាមបែបប្រពៃណី", Medi-Cal "ដែលទៀងត្រង់" ឬ Medi-Cal ធម្មតា) ដែលអ្នកទៅកាន់អ្នកសេវាថែទាំណាម្នាក់ដែលទទួលយក Medi-Cal។

## 7. តើខ្ញុំនៅតែទទួលបាន EPSDT ដែរឬទេ ប្រសិនបើខ្ញុំស្ថិតនៅក្នុងការថែទាំដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ Medi-Cal?

បាទ/ចាស អ្នកនៅតែទទួលបាន។ ប្រសិនបើអ្នកទទួលបាន Medi-Cal តាមរយៈផែនការថែទាំដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ Medi-Cal អ្នកនៅតែទទួលបានអត្ថប្រយោជន៍នានានៃ EPSDT។ អ្នកមានសិទ្ធិដូចគ្នានឹងសិទ្ធិដែលអ្នកមាននៅពេលដែលអ្នកស្ថិតនៅក្នុងសេវា Medi-Cal ដែលត្រូវទូទាត់ប្រាក់កម្រៃដែរ។

## 8. តើ EPSDT ដំណើរការយ៉ាងដូចម្តេចខ្លះ នៅពេលដែលខ្ញុំស្ថិតនៅក្នុងការថែទាំដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ Medi-Cal?

ផែនការថែទាំដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ Medi-Cal ត្រូវតែផ្តល់ជូនអ្នកនូវអត្ថប្រយោជន៍នានានៃ EPSDT ស្របតាមច្បាប់រដ្ឋ និងច្បាប់សហព័ន្ធ។ ពួកគេត្រូវតែប្រើប្រាស់ស្តង់ដារនៃភាពចាំបាច់ផ្នែកវេជ្ជសាស្ត្ររបស់ EPSDT នៅពេលធ្វើសេចក្តីសម្រេចថាតើត្រូវផ្តល់ការអនុញ្ញាតដល់សេវាណាមួយដែរឬទេ។ ផែនការថែទាំដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ Medi-Cal ត្រូវតែផ្តល់ជូនអ្នកនូវការគ្រប់គ្រងករណីគ្រប់ជ្រុងជ្រោយ ធ្វើការសម្របសម្រួលការថែទាំ និងទទួលខុសត្រូវជាចម្បងចំពោះការផ្តល់ជូននូវរាល់សេវាគ្រប់ប្រភេទដែលមានភាពចាំបាច់ផ្នែកវេជ្ជសាស្ត្រ ទោះបីជាកម្មវិធីផ្សេងទៀត ដូចជាសាលារៀន មជ្ឈមណ្ឌលនានានៅតាមតំបន់ ឬកម្មវិធីផ្សេងទៀត អាចផ្តល់ជូននូវសេវាទាំងនោះក៏ដោយ។ កុមារមិនត្រូវបានតម្រូវឲ្យប្រើប្រាស់គ្រប់សេវាទាំងអស់នៅក្នុងកម្មវិធីទាំងនេះ មុនពេលដែល ផែនការថែទាំដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ Medi-Cal ត្រូវទទួលខុសត្រូវចំពោះសេវាទាំងនោះនោះទេ។ មានសេវានានាដែលត្រូវបាន "បង្កើតឡើង" ដោយការថែទាំដែលស្ថិតនៅក្រោមការគ្រប់គ្រង និងមិនស្ថិតនៅក្រោមទំនួលខុសត្រូវរបស់ផែនការថែទាំដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ Medi-Cal ក្នុងការផ្តល់ជូននូវសេវាទាំងនោះទេ។

សេវាទាំងនេះរួមមាន សេវាផ្នែកទន្តសាស្ត្រដែលត្រូវបានគ្រប់ដណ្តប់ដោយកម្មវិធី Denti-Cal និងសេវាសុខភាពខួរក្បាលឯកទេសនានា។ [10]

## 9. ខ្ញុំមិនពេញចិត្តនឹងសេចក្តីសម្រេចណាមួយនៃផែនការថែទាំដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្ញុំ តើខ្ញុំអាចធ្វើអ្វីបានខ្លះ?

ចូរអានមូលហេតុដែលសេវានោះត្រូវបានបដិសេធ ឬត្រូវបានកាត់បន្ថយ និងស្តង់ដារនៃភាពចាំបាច់ផ្នែកវេជ្ជសាស្ត្រ ដែលផែនការថែទាំដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ Medi-Cal របស់អ្នក កំពុងតែប្រើប្រាស់។ ប្រសិនបើផែនការថែទាំដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ Medi-Cal របស់អ្នក មិនបានលើកឡើងអំពី EPSDT នៅក្នុងមូលហេតុនៃការបដិសេធរបស់ខ្លួនទេនោះ នៅពេលនោះផែនការនោះអាចកំពុងតែប្រើប្រាស់ស្តង់ដារនៃភាពចាំបាច់ផ្នែកវេជ្ជសាស្ត្រដែលខុសឆ្គង។ ប្រសិនបើផែនការថែទាំដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ Medi-Cal របស់អ្នក និយាយថា “ទេ” ដោយសារតែសេវានោះមិនត្រូវបានគ្របដណ្តប់ នោះទេ នោះវាប្រាប់អ្នកថា វាប្រហែលជាមិនបានពិចារណាអំពី អត្ថប្រយោជន៍បន្ថែមនានាដែលអាចស្វែងរកបានតាមរយៈ EPSDT នោះទេ។

ប្រសិនបើអ្នកមិនពេញចិត្តចំពោះសេចក្តីសម្រេចរបស់ផែនការថែទាំដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ Medi-Cal របស់អ្នកទេនោះ អ្នកអាចដាក់បណ្តឹងសារទុក្ខ និង/ឬបណ្តឹងតវ៉ាបាន។ ចាប់តាំងពីថ្ងៃទី 1 ខែកក្កដា ឆ្នាំ 2017 មក វិធាននានាសម្រាប់បណ្តឹងសារទុក្ខ និងបណ្តឹងតវ៉ាត្រូវបានកែប្រែ។ សម្រាប់ព័ត៌មាននានា ចូរមើលៈ លិខិតនៃផែនការទាំងអស់ 17-006 នៅៈ

http://www.dhcs.ca.gov/formsandpubs/Documents/MMCDAPLsandPolicyLetters/APL2017/APL17-006.pdf។
អ្នកក៏អាចអានឯកសារផ្សព្វផ្សាយរបស់យើងអំពីប្រធានបទនេះបានផងដែរ នៅ https://www.disabilityrightsca.org/publications/medi-cal-managed-care-appeals-and-grievances។

---

សម្គាល់៖ ប្រសិនបើអ្នកស្ថិតនៅក្នុងសេវា Medi-Cal ដែលត្រូវទទួលប្រាក់កម្រៃ អ្នកអាចដាក់ពាក្យស្នើសុំបើកសវនាការជំសុក្រឹតមួយអំពី Medi-Cal បាន។ [11]
យើងចង់ទទួលបានមតិយោបល់របស់អ្នក! សូមបំពេញ កម្រងសំណួរអង្កេត អំពីការផ្សព្វផ្សាយ របស់យើងខ្ញុំ ហើយប្រាប់យើងខ្ញុំ ពីយោបល់លោកអ្នកផង! [ធ្វើការស្ទង់មតិ]

សម្រាប់ជំនួយផ្នែកច្បាប់ សូមហៅទូរស័ព្ទ ទៅលេខ 800-776-5746 ឬ បំពេញ ទម្រង់បែបបទសំណើសុំជំនួយ។ សម្រាប់គោលបំណងផ្សេងៗ ទៀត សូមទៅទូរស័ព្ទ ទៅលេខ 916-504-5800 (កាលីហ្វ័រញ៉ាខាងជើង); 213-213-8000 (កាលីហ្វ័រញ៉ាខាងត្បូង)។

*សិទ្ធិរបស់ជនពិការនៃរដ្ឋកាលីហ្វ័រញ៉ាបានទទួលមូលនិធិពីប្រភពខុសៗគ្នាជាច្រើន សម្រាប់បញ្ជីអ្នកផ្តល់មូលនិធិពេញលេញ សូមចូលទៅកាន់* http://www.disabilityrightsca.org/Documents/ListofGrantsAndContracts.html។

---

1 Medicaid គឺត្រូវបានស្គាល់ជា Medi-Cal នៅកាលីហ្វ័រញ៉ា។ -
(ត្រលប់ទៅឯកសារមេ)

2 Medi-Cal ទំហំពេញលេញ មានន័យថាសេវាកម្មទាំងអស់ដែលអាចរកបាន នៅក្រោម Medi-Cal។ Medi-Cal ទំហំពេញលេញមិនរាប់បញ្ចូលតែសេវា ទាំងនោះដែលមាន Medi-Cal. សង្គ្រោះបន្ទាន់ប៉ុណ្ណោះឡើយ –
(ត្រលប់ទៅឯកសារមេ)

3 22 CCR § 51340; http://www.dhcs.ca.gov/services/Pages/EPSDT.aspx
(ត្រលប់ទៅឯកសារមេ)

4 42 USC §1396d(r); 22 CCR §§ 51340, 51340.1, 51184;
http://www.dhcs.ca.gov/services/MH/Documents/PPQA%20Pages/Katie%20A/Medi-Cal_Manual_Third_Edition.pdf
(ត្រលប់ទៅឯកសារមេ)

5 42 USC § 1396d(r)(5); 22 CCR §§ 51340 និង 51340.1
(ត្រលប់ទៅឯកសារមេ)

6 សម្រាប់ព័ត៌មានអំពីកាលីហ្វ័រញ៉ាដែលបានធានារ៉ាប់រង សូមមើល៖
https://www.coveredca.com/ https://www.affordablecarecalifornia.org

---

(ត្រលប់ទៅឯកសារមេ)
[7] មើល DRC ឯកសារបោះពុម្ព #555101 – "តើអ្វីទៅជាការពង្រីកមនុស្សពេញវ័យ/MAGI Medi-Cal?" នៅ https://www.disabilityrightsca.org/publications/what-is-adult-expansion-magi-medi-cal
(ត្រលប់ទៅឯកសារមេ)
[8] មើល http://www.dhcs.ca.gov/services/ccs/Pages/default.aspx
(ត្រលប់ទៅឯកសារមេ)
[9] សម្រាប់ព័ត៌មានបន្ថែមអំពីការថែទាំដែលគ្រប់គ្រងដោយ Medi-Cal មើល DRC ឯកសារបោះពុម្ព # 549501, នៅ https://www.disabilityrightsca.org/publications/medi-cal-managed-care-health-plans-what-are-they-what-do-i-need-to-know-about-them និង # 554501។ មើលផងដែរ - ការថែទាំដែលគ្រប់គ្រងដោយ Medi-Cal៖ "ការបន្តនូវការថែទាំ" នៅ៖ https://www.disabilityrightsca.org/publications/medi-cal-managed-care-continuity-of-care ប្រសិនបើអ្នកស្ថិតក្នុងផែនការសុខភាពដែលបានគ្រប់គ្រងរួចហើយ ហើយត្រូវការមើលអ្នកផ្តល់សេវានៅក្រៅបណ្តាញម្នាក់ សូមមើល DRC ឯកសារបោះពុម្ព #555901 នៅ https://www.disabilityrightsca.org/publications/medi-cal-managed-care-out-of-network-services
(ត្រលប់ទៅឯកសារមេ)
[10] មើលលិខិតនៃផែនការទាំងអស់ 14-017 ៖ តម្រូវការសម្រាប់ការធានារ៉ាប់រងនៃមុនពេល និងតាមពេលនីមួយ ៖ សេវាពិនិត្យ វិនិច្ឆ័យ និងព្យាបាលសម្រាប់អ្នកទទួលផល Medi-Cal ក្រោមម្ភៃមួយឆ្នាំនៅ៖ http://www.dhcs.ca.gov/formsandpubs/Documents/MMCDAPLsandPolicyLetters/APL2014/APL14-017.pdf -(ត្រលប់ទៅឯកសារមេ)
[11] ដើម្បីស្នើសុំសវនាការយុត្តិធម៌ Medi-Cal មួយ ពិនិត្យឡើងវិញសេចក្តីជូនដំណឹងនៃចំណាត់ការរបស់អ្នកសម្រាប់ព័ត៌មានអំពីរបៀបស្នើសុំសវនាការយុត្តិធម៌មួយ និងកាលបរិច្ឆេទកំណត់សម្រាប់ការស្នើសុំសវនាការយុត្តិធម៌មួយ និងការរង់ចាំជំនួយបង់ថ្លៃ។ ចូលទៅកាន់ផងដែរ៖
http://www.cdss.ca.gov/Hearing-Requests និង http://www.dhcs.ca.gov/services/medi-cal/Pages/Medi-CalFairHearing.aspx
(ត្រលប់ទៅឯកសារ)